## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

-សំណុំរឿងព្រហ្មទណ្ឌ លេខៈ ១២៥៦ អក

ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦

-សាលក្រមលេខៈ ២៥ (ឃ)

ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

### តាងនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមាន សមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះបណ្តឹងទាស់លើសាលក្រមលេខៈ ៧៤ (ញ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ សំណុំរឿងព្រហ្មទណ្ឌលេខៈ ១២៥៦ អក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ដែលមានពិរុទ្ធជនដូចខាងក្រោម ៖

-ឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] អាង (រ) ម្តាយឈ្មោះ[redacted] យ៉ន (រ) នៅលីវ ។ (ឃុំខ្លួនថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩)

ជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ដោយមានមេធាវី [redacted] និងមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] ចាន់រ៉ា។

### អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ១០ និង ៣០នាទី កម្លាំងកងរាជអាវុធហត្ថស្រុកខ្សាច់កណ្តាល កំពុងធ្វើការល្បាតចល័តក្នុងភូមិសាស្ត្រនៅចំណុចក្នុងក្រុមហ៊ុន 7NG ស្ថិតនៅក្នុងភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ក៏ប្រទះឃើញជនសង្ស័យឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន គួរឱ្យសង្ស័យក៏បានហៅឈប់ត្រួតពិនិត្យ និងឆែកឆេរឃើញថ្នាំញៀន (ម៉ាទឹកកក) ចំនួន ០៥កញ្ចប់តូច ក៏នាំមកអង្គភាពសួរនាំតែម្តង ។ តាមចម្លើយសារភាពរបស់ជនសង្ស័យទាំងពីរនាក់ ថា ឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ជាអ្នកប្រើឱ្យពួកខ្លួនយកថ្នាំញៀនទៅលក់ឱ្យគេ ។

បានឃើញ សាលក្រមលេខៈ ៧៤ (ញ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាលដែលមានខ្លឹមសារ ៖

១-ផ្តន្ទាទោសលើជនជាប់ចោទ ៖



Scanned with CamScanner

១.១.ឈ្មោះ [redacted] សុភ័ស្ត ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារចំនួន ០១ (មួយ) ឆ្នាំ ។

១.២.ឈ្មោះ [redacted] ធិន ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារចំនួន ០១ (មួយ) ឆ្នាំ ។

១.៣.ឈ្មោះ [redacted] ចាន់រ៉ា ភេទប្រុស អាយុ ២១ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៣ (បី) ឆ្នាំ ។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-រឹបអូសវត្ថុដែលចាប់យកមាន ម៉េ្សាក្រាមពណ៌សថ្លា ជាសារធាតុញៀន ប្រភេទម៉ាទឹកកក ចំនួន ប្រាំកញ្ចប់តូច មានទម្ងន់ ០.៣៦ ក្រាម ដាក់ក្នុងស្រោមសំបុត្រធំចំនួន ពីរ ពណ៌សបិទជិតមានលេខកូដ ០០១៥៥៤ និង ០០១៥៥៥ និងទូរស័ព្ទដៃម៉ាកណូគាស៊េរីចាស់ មានពណ៌ខៀវ និងពណ៌ស ។

-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុភ័ស្ត , ឈ្មោះ [redacted] ធិន និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ា ។

ទុកសិទ្ធិឲ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ ពាក្យសុំប្ដឹងទាស់ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ដែលមានខ្លឹមសារៈ

"សុំប្ដឹងទាស់ និងសាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខៈ ៧៤ (ញ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្ដាល ។

## នាពេលសវនាការ

-ពិរុទ្ធជនឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ បានឆ្លើយថា ខ្លួនសុំប្ដឹងទាស់ ព្រោះខ្លួនមិនសុខចិត្តនិងការសម្រេចសេចក្ដីនេះ ។ ខ្លួនមិនបានធ្វើសកម្មភាពជួញដូរថ្នាំញៀនដូចការចោទប្រកាន់នោះទេ ដោយសារនៅពេលសមត្ថកិច្ចធ្វើការឃាត់ខ្លួនឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន គឺខ្លួនមិនបាននៅកន្លែងកើតហេតុនោះទេ ហើយខ្លួនក៏មិនដែលបានប្រើអោយអ្នកទាំងពីរយកថ្នាំញៀនទៅលក់ឱ្យអ្នកណាដែរ ។ ខ្លួនមិនដែលធ្វើសកម្មភាពក្នុងការជួញដូរថ្នាំញៀននោះទេ។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន ព្រោះធ្លាប់ចូលលុយគ្នាទិញគ្រឿងញៀនយកមកប្រើប្រាស់ ហើយអ្នកទាំងពីរនាក់នោះ ជាអ្នកទៅទិញថ្នាំញៀន។ ខ្លួនមិនធ្លាប់លក់គ្រឿងញៀននោះទេ។ ពីមុនមក ខ្លួនធ្លាប់ជាប់ពន្ធនាគារពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅពន្ធនាគាររាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០១៧។ ពេលដែលខ្លួន ត្រូវបានគេចាប់ខ្លួននោះ មិនមានថ្នាំញៀននោះទេ។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានថាៈ ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ និងបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់ដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល ។



Scanned with CamScanner

-មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យពិរុទ្ធជនឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ធ្វើសេចក្តីសន្និដ្ឋានថាៈ ខ្ញុំសុំធ្វើការរៀបរាប់អង្គហេតុ និងសេចក្តីសន្និដ្ឋានដូចតទៅ កូនក្តីខ្លួន ធ្លាប់បានសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ០២ឆ្នាំ ០៦ខែ ហើយបានអនុវត្តទោសចប់សព្វគ្រប់រួច អគ្គនាយកដ្ឋានពន្ធនាគារ បានចេញដីកាបង្គាប់ឱ្យដោះលែង កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ តាមរយៈដីកាបង្គាប់ឱ្យដោះលែងលេខ ២៨៤៩ អយក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ បន្ទាប់ពីបានដោះលែងរួចមក នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ដោយយោងតាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ២៤៧ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ ក្រោយពីមានការចាប់ខ្លួននេះ កូនក្តីខ្ញុំ បានដឹងថា សាលាដំបូងខេត្តកណ្តាល បានចោទប្រកាន់ខ្លួនពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ០៣ឆ្នាំ តាមរយៈសាលក្រមកំបាំងមុខលេខ ៧៤ (ញ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ ដោយកំបាំងមុខកូនក្តីខ្ញុំ។ សាលក្រមកំបាំងមុខនេះ បានចេញក្រោយពេលដែលកូនក្តីខ្ញុំ កំពុងតែអនុវត្តទោសដាក់ពន្ធនាគារនៅមណ្ឌលកែប្រែទី១។ ផ្អែកតាមអង្គហេតុដែលបានបញ្ជាក់ជូនខាងលើ ឃើញថា កូនក្តីខ្ញុំ ត្រូវបានសាលាដំបូងខេត្តកណ្តាល សម្រេចផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ០៣ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយកំបាំងមុខ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ១២៥៦ អក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្តាល គឺឈ្មោះ [redacted] ចាន់រ៉ា មិនបានចូលរួមឆ្លើយបំភ្លឺ និងមិនមានឱកាសដាក់ភស្តុតាងដោះបន្ទុកខ្លួននោះទេ។ ផ្ទុយទៅវិញ កូនក្តីខ្ញុំ ត្រូវបានចោទប្រកាន់ដោយគ្មានភស្តុតាងជាក់ស្តែង ត្រឹមជាចម្លើយដាក់បន្ទុកពីសំណាក់ជនជាប់ចោទឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន ប៉ុណ្ណោះ។ ក្នុងអំឡុងពេលដំណើរសំណុំរឿងសាលាដំបូងខេត្តកណ្តាលនេះ កូនក្តីខ្ញុំកំពុងអនុវត្តទោសផ្ទាល់ខ្លួន នៅមណ្ឌលអប់រំកែប្រែទី១ ដែលត្រូវបានផ្តន្ទាទោសរយៈពេល ០២ឆ្នាំ០៦ខែ របស់សាលាដំបូងរាជធានីភ្នំពេញ។ កូនក្តីខ្ញុំ មិនមានគោលបំណងក្នុងការគេចវេះក្នុងការចូលរួមដំណើរនីតិវិធីរបស់សាលាដំបូងខេត្តកណ្តាលនោះទេ។ តើការសម្រេចផ្តន្ទាទោសកូនក្តីខ្ញុំដូចខាងលើ តើត្រឹមត្រូវ និងសមហេតុផល ដែរឬទេ? ជនជាប់ចោទឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន បានឆ្លើយចោទប្រកាន់កូនក្តីខ្ញុំថា ជាអ្នកផ្ញើគ្រឿងញៀនឱ្យខ្លួនយកទៅលក់ ប៉ុន្តែជាក់ស្តែងក្នុងថ្ងៃចាប់ខ្លួន មិនមានវត្តមានកូនក្តីនាងខ្ញុំឡើយ និងមិនមានភស្តុតាងដាក់បន្ទុកណាមួយក្នុងការចោទប្រកាន់កូនក្តីខ្ញុំនោះទេ ជនទាំងពីរនាក់នោះ ដឹងថា កូនក្តីខ្ញុំមិនអាចឆ្លើយបំភ្លឺក៏មានគំនិតទុច្ចរិតឆ្លើយដាក់បន្ទុកលើកូនក្តីនាងខ្ញុំតែម្តង។ កូនក្តីនាងខ្ញុំ ត្រូវទទួលការផ្តន្ទាទោសយ៉ាងអយុត្តិធម៌ ព្រោះកូនក្តីនាងខ្ញុំ ពុំបានដឹងទាល់តែសោះថាខ្លួនចោទប្រកាន់នៅសាលាដំបូងខេត្តកណ្តាលបន្ថែមទៀត។ យោងតាមអង្គហេតុ និងអង្គច្បាប់ខាងលើ ឃើញថា កូនក្តីនាងខ្ញុំ ពិតជារងគ្រោះនូវការសម្រេចក្តីដោយអយុត្តិធម៌ ដោយសារមូលដ្ឋាននៃការសម្រេចទោសដោយការបំភ័ន្ត បំភ្លឺ របស់ឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន និងមិនមានភស្តុតាងដាក់បន្ទុកចាប់បាននៅកន្លែងកើតហេតុនោះទេ។ លើសពីនេះទៅទៀត កូនក្តីនាងខ្ញុំគ្មានបំណងធ្វើការគេចវេះ មិនចូលរួមដំណើរសំណុំរឿងនៅសាលាដំបូងខេត្តកណ្តាល នោះដែរ ប៉ុន្តែដោយសារកំពុងជាប់ឃុំនៅមណ្ឌលកែប្រែទី១ ទើបគ្មានឱកាសពីការចោទប្រកាន់បន្ថែមទៀតនៅសាលាដំបូងខេត្តកណ្តាល។ កូនក្តីនាងខ្ញុំ ក៏បានអនុវត្តទោសចប់សព្វគ្រប់នៅមណ្ឌលកែប្រែទី១ និងបានកែប្រែខ្លួនក្លាយជាបុគ្គលល្អក្នុងសង្គម សារជាថ្មីផងដែរ។ នាងខ្ញុំជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ សូមសំណូមពរឱ្យលោកស្រីចៅក្រម និងតំណាងអយ្យការ សម្រេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទប្រកាន់ និងអនុញ្ញាតឱ្យកូនក្តីនាងខ្ញុំ មានសេរីភាពឡើងវិញ។



Scanned with CamScanner

-សំដីចុងក្រោយរបស់ពិរុទ្ធជនឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ សំណូមពរអោយតុលាការមេត្តាសម្រេចឱ្យខ្ញុំបានរួចផុតបទចោទប្រកាន់ ។

ក្រោយពីបានស្តាប់ចម្លើយពិរុទ្ធជន

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ពិរុទ្ធជន

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

-តាមកំណត់ហេតុសួរចម្លើយ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ពិរុទ្ធជនឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ភេទប្រុស កើតឆ្នាំ១៩៩៤ បានប្រកាសប្តឹងទាស់នឹងសាលក្រមលេខ ៧៤ (ញ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល គឺធ្វើឡើងក្នុងកំណត់ច្បាប់ ដែលអាចឱ្យតុលាការលើកយកមកពិចារណាបាន តាមបញ្ញត្តិមាត្រា ៣៦២ និងមាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-តាមចម្លើយពិរុទ្ធជនឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ បានឆ្លើយថា ខ្លួនសុំប្តឹងទាស់ ព្រោះខ្លួនមិនសុខចិត្ត និងការសម្រេចសេចក្តីនេះ ។ ខ្លួនមិនបានធ្វើសកម្មភាពជួញដូរថ្នាំញៀនដូចការចោទប្រកាន់នោះទេ ដោយសារនៅពេលសមត្ថកិច្ចធ្វើការឃាត់ខ្លួនឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន គឺខ្លួនមិនបាននៅកន្លែងកើតហេតុនោះទេ ហើយខ្លួនក៏មិនដែលបានប្រើអោយអ្នកទាំងពីរយកថ្នាំញៀនទៅលក់ឱ្យអ្នកណាដែរ ។ ខ្លួនមិនដែលធ្វើសកម្មភាពក្នុងការជួញដូរថ្នាំញៀននោះទេ។ ខ្លួនធ្លាប់ស្គាល់ឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន ព្រោះធ្លាប់ចូលលុយគ្នាទិញគ្រឿងញៀនយកមកប្រើប្រាស់ ហើយអ្នកទាំងពីរនាក់នោះ ជាអ្នកទៅទិញថ្នាំញៀន។ ខ្លួនមិនធ្លាប់លក់គ្រឿងញៀននោះទេ។ ពីមុនមក ខ្លួនធ្លាប់ជាប់ពន្ធនាគារពីបទ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅពន្ធនាគាររាជធានីភ្នំពេញ កាលពីខែមេសា ឆ្នាំ២០១៧។ ពេលដែលខ្លួន ត្រូវបានគេចាប់ខ្លួននោះ មិនមានថ្នាំញៀននោះទេ។

-តំណាងអយ្យការសន្និដ្ឋាន បានសន្និដ្ឋានថា ពិតជាមានភស្តុតាងគ្រប់គ្រាន់លើឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ បានប្រព្រឹត្តបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន និងសុំរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរជាមូលដ្ឋាន ។

-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្លួន ឈ្មោះ [redacted] ចាន់រ៉ា រួចផុតពីបទចោទប្រកាន់។ តុលាការនឹងពិនិត្យពិចារណា។

-តាមសាលក្រមព្រហ្មទណ្ឌលេខៈ ៧៤ (ញ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ពិតជាបានប្រព្រឹត្តបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ដាក់ពន្ធនាគាររយៈពេល ០៣ (បី) ឆ្នាំ ។

-តាមចម្លើយរបស់ពិរុទ្ធជនឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ, សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន, សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងការពិនិត្យសំណុំរឿង ឃើញថា ឈ្មោះ [redacted] ចាន់រ៉ា បានឆ្លើយ



Scanned with CamScanner

បដិសេធថា រូបខ្លួនមិនបានផ្ញើគ្រឿងញៀននិងឈ្មោះ[redacted]សុភ័ស្ត និងឈ្មោះ[redacted] ធិន ឱ្យទុកលក់ឱ្យ គេនោះទេ ខ្លួនមិនដែលលក់គ្រឿងញៀនទេ ខ្លួនគ្រាន់តែធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ[redacted]សុភ័ស្ត និងឈ្មោះ[redacted] ធិន ហើយខ្លួនបានចូលលុយគ្នាជាមួយឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន ដើម្បីទិញថ្នាំញៀនយកមកប្រើប្រាស់រួមគ្នា ដោយឈ្មោះ[redacted] សុភ័ស្ត និងឈ្មោះ [redacted] ធិន ជាអ្នកឡើងទៅទិញ។ តុលាការ យល់ឃើញថា មិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ចាន់រ៉ា ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នោះទេ។ ប៉ុន្តែ ពិរុទ្ធជនឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ បានឆ្លើយសារភាពថា ខ្លួនបានចូលលុយគ្នាជាមួយឈ្មោះ [redacted] សុភ័ស្ត និងឈ្មោះ[redacted] ធិន ដើម្បីទិញថ្នាំញៀនយកមកប្រើប្រាស់។ អំពើនេះ ជាអំពើ ប៉ុនប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដ។ ហេតុដូច្នេះ គប្បីតុលាការកែប្រែបទចោទប្រកាន់លើឈ្មោះ[redacted] ចាន់រ៉ា ហៅ ខ្មៅ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ ប៉ុនប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៧៤ (ញ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល ប៉ុន្តែកែប្រែចំណុចផ្តន្ទាទោសលើឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ភេទប្រុស កើតឆ្នាំ១៩៩៤ ដូចខាងក្រោម៖

១.១. កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ភេទប្រុស កើតឆ្នាំ១៩៩៤ ជនជាតិខ្មែរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន មកបទ ប៉ុនប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១.២. ផ្តន្ទាទោសឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ ភេទប្រុស កើតឆ្នាំ១៩៩៤ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ (បួន) ខែ ពីបទ ប៉ុនប៉ងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-បញ្ឈប់ដីកាចាប់ខ្លួន-ឃុំខ្លួនលើឈ្មោះ[redacted]ចាន់រ៉ា ហៅ ខ្មៅ គិតពីថ្ងៃប្រកាសសាលក្រម។

៣-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខពិរុទ្ធជនឈ្មោះ [redacted] ចាន់រ៉ា ហៅ ខ្មៅ និងមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន។

ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ ហត្ថលេខា និងត្រា** **ចៅក្រមជំនុំជម្រះ ហត្ថលេខា និងត្រា**

[redacted] [redacted]

-បានចម្លងត្រឹមត្រូវតាមច្បាប់ដើម-

ថ្ងៃសុក្រ ៦កើត ខែផល្គុន ឆ្នាំជូត ឯកស័ក ព.ស ២៥៦៣

កណ្តាល ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner